# ៧ ដំណាក់កាល ពីការចាប់ខ្លួន រហូតដល់បណ្តឹងឧទ្ធរណ៍

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
កម្ពុជា

## ១- ការចាប់ខ្លួន៖



អ្នកអាចត្រូវបានចាប់ខ្លួន ករណីមានមូលហេតុសមស្រប និងសង្ស័យថាអ្នកបានប្រព្រឹត្តបទល្មើសណាមួយ។ មន្ត្រីនគរបាល នឹងនាំខ្លួនអ្នកយកទៅប៉ុស្តិ៍នគរបាល។ ប្រសិនបើអ្នកមិនសហការ ឬរឹងទទឹងនឹងការចាប់ខ្លួននេះ មន្ត្រីនគរបាលអាចនឹងប្រើកម្លាំងបង្ខំចាប់ខ្លួនអ្នក។ ប្រសិនបើបទល្មើសមិនធ្ងន់ធ្ងរ មន្ត្រីនគរបាល អាចដោះលែងអ្នកពីប៉ុស្តិ៍នគរបាល។

## ២- ការសួរចម្លើយ និងការឃាត់ខ្លួន៖



មន្ត្រីនគរបាល នឹងសួរចម្លើយអ្នកនៅប៉ុស្តិ៍នគរបាល។ មន្ត្រីនគរបាល នឹងប្រាប់អ្នកភ្លាមអំពីមូលហេតុនៃការឃាត់ខ្លួននេះ។ អ្នកនឹងត្រូវផ្តល់ឱកាសឲ្យឆ្លើយបំភ្លឺនូវរឿងហេតុដែលបានកើតឡើង និងត្រូវបានកត់ត្រាក្នុងកំណត់ហេតុជាផ្លូវការ ដើម្បីដាក់ជូនតុលាការ។ អ្នកមានសិទ្ធិនៅស្ងៀមមិននិយាយអ្វីទាំងអស់ រហូតដល់អ្នកទទួលបានមេធាវីការពារ។ ប្រសិនបើមន្ត្រីនគរបាល ធ្វើទារុណកម្មអ្នក ដើម្បីឲ្យអ្នកឆ្លើយសារភាពនោះជាអំពើខុសច្បាប់។ ក្រោយពេលសាកសួរ មន្ត្រីនគរបាល អាចសម្រេចដោះលែងអ្នក ឬ ឃាត់ខ្លួនអ្នករហូតដល់ ៤៨ ម៉ោង (២ថ្ងៃ)។ មន្ត្រីនគរបាល អាចពន្យាពេលឃាត់ខ្លួននេះ ២៤ ម៉ោងបន្ថែមទៀត លើកលែងតែអ្នកមានអាយុក្រោម ១៨ ឆ្នាំ។ អ្នកមានសិទ្ធិជួបមេធាវី ឬសាច់ញាតិរបស់អ្នក បន្ទាប់ពីរយៈពេល ២៤ ម៉ោងកន្លងផុត។ អ្នកក៏មានសិទ្ធិទទួលបានជំនួយព្យាបាលនានាពីគ្រូពេទ្យបានគ្រប់ពេល ក្នុងអំឡុងពេលឃាត់ខ្លួន។

## ៣- តុលាការ - ដំណាក់កាលអយ្យការ៖



មន្ត្រីនគរបាល នឹងបញ្ជូនខ្លួនអ្នកចេញពីប៉ុស្តិ៍នគរបាលទៅកាន់តុលាការឲ្យបានឆាប់បំផុតតាមដែលអាចធ្វើបាន តែមិនឲ្យលើសរយៈពេល ៤៨ ម៉ោង (២ថ្ងៃ) ឬបន្ទាប់ពីពន្យាពេល ២៤ ម៉ោងរួចហើយ។ នៅតុលាការ ព្រះរាជអាជ្ញា នឹងសួរចម្លើយអ្នក ហើយនឹងសម្រេចចោទប្រកាន់អ្នកអំពីបទល្មើសណាមួយ ឬសម្រេចមិនធ្វើការចោទប្រកាន់អ្នក និងដោះលែងអ្នក។ ប្រសិនបើអ្នកត្រូវបានចោទប្រកាន់ពីបទល្មើសណាមួយដែលមានលក្ខណៈស្មុគស្មាញ (បទឧក្រិដ្ឋ) ព្រះរាជអាជ្ញានឹងបញ្ជូនសំណុំរឿងរបស់អ្នកទៅចៅក្រមស៊ើបសួរ ដើម្បីធ្វើការស៊ើបសួរបន្ត ហើយនឹងអាចស្នើសុំឲ្យចៅក្រមស៊ើបសួរឲ្យឃុំខ្លួនអ្នកបណ្តោះអាសន្ននៅពន្ធនាគារ ។

## ៤- តុលាការ - ដំណាក់កាលចៅក្រមស៊ើបសួរ៖



ចៅក្រមស៊ើបសួរ នឹងធ្វើការស៊ើបសួរលើសំណុំរឿងរបស់អ្នក។ ប្រសិនបើអ្នកត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ឬប្រសិនបើអ្នកជាអនីតិជន សំណុំរឿងក្តីរបស់អ្នកមិនអាចប្រព្រឹត្តទៅដោយគ្មានមេធាវីបានទេ។ នៅពេលអ្នកបង្ហាញខ្លួនដំបូងនៅតុលាការចំពោះមុខចៅក្រមស៊ើបសួរ ចៅក្រមស៊ើបសួរ នឹងសម្រេចថាដោះលែងអ្នក ឬដាក់អ្នកអោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬឃុំខ្លួនអ្នកបណ្តោះអាសន្ននៅក្នុងពន្ធនាគារអំឡុងពេលស៊ើបសួរ។ ចៅក្រមស៊ើបសួរ ត្រូវតែប្រាប់អ្នកអំពីមូលហេតុនៃការដាក់អោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬឃុំខ្លួនបណ្តោះអាសន្ននេះ និងទទួលការកត់សម្គាល់របស់អ្នក។ រយៈពេលអតិបរមានៃការឃុំខ្លួនបណ្តោះអាសន្ន មានរយៈពេលខុសៗគ្នា ទៅតាមអាយុរបស់អ្នក និងបទល្មើសដែលបានចោទប្រកាន់។ អ្នក ឬមេធាវីរបស់អ្នក អាចដាក់ពាក្យសុំឲ្យដោះលែងនៅក្រៅឃុំបានគ្រប់ពេលវេលា ទៅចៅក្រមស៊ើបសួរ។ ប្រសិនបើពាក្យសុំនេះត្រូវបានសម្រេចបដិសេធ អ្នក ឬមេធាវីរបស់អ្នក អាចដាក់ពាក្យសុំជាថ្មីម្តងទៀតក្នុងរយៈពេល១ខែ បន្ទាប់ពីមានសេចក្តីសម្រេចបដិសេធពាក្យសុំលើកមុន ទៅចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរ។ នៅពេលបិទការស៊ើបសួរ ចៅក្រមស៊ើបសួរ អាចបញ្ជូនសំណុំរឿងអ្នកទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់។ ប្រសិនបើចៅក្រមស៊ើបសួរ សម្រេចលើកលែងការចោទប្រកាន់ អ្នកនឹងត្រូវបានដោះលែង។ ប៉ុន្តែបើចៅក្រមស៊ើបសួរនៅតែរក្សាការចោទប្រកាន់ អ្នកនឹងត្រូវបន្តឃុំខ្លួននៅក្នុងពន្ធនាគាររហូតដល់ថ្ងៃសវនាការ ឬអាចដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្នរហូតដល់ថ្ងៃសវនាការ។ អ្នកនៅតែអាចបន្តការស្នើសុំឲ្យដោះលែងអ្នក រហូតដល់ពេលសវនាការ។ អ្នកនឹងត្រូវបានដោះលែងឲ្យនៅក្រៅឃុំដោយឯកឯង ប្រសិនបើអ្នកមិនត្រូវបានយកមកជំនុំជម្រះ ក្នុងរយៈពេល ៤ ខែ បន្ទាប់ពីបញ្ចប់ការស៊ើបសួរ។

## ៥- ការជំនុំជម្រះ - សវនាការ៖



នៅក្នុងដំណាក់កាលជំនុំជម្រះ ប្រសិនបើអ្នកត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ឬអ្នកជាអនីតិជន អ្នកត្រូវមានជំនួយរបស់មេធាវីដាច់ខាត។ ក្នុងអំឡុងពេលសវនាការ អ្នកនឹងត្រូវសាកសួរដោយចៅក្រម ព្រះរាជអាជ្ញា និងមេធាវី។ អ្នកត្រូវបានសន្មតថាគ្មានទោស រហូតដល់តុលាការសម្រេចថាមានពិរុទ្ធ។ អ្នកអាចទទួលយកការចោទប្រកាន់ ឬ មិនទទួលយកការចោទប្រកាន់របស់តុលាការ។ បើអ្នកគ្មានលទ្ធភាពជ្រើសរើសមេធាវី អ្នកនឹងត្រូវផ្តល់ជំនួយមេធាវីដោយឥតគិតកម្រៃ។ អ្នកនឹងត្រូវផ្តល់សិទ្ធិអោយនិយាយសំដីចុងក្រោយ។ នៅចុងបញ្ចប់សវនាការ ប្រសិនបើចៅក្រមពិនិត្យឃើញថា អ្នកគ្មានពិរុទ្ធ អ្នកនឹងត្រូវបានដោះលែង តែបើពិនិត្យឃើញថាអ្នកមានពិរុទ្ធ អ្នកនឹងត្រូវបានផ្តន្ទាទោសតាមច្បាប់កំណត់។

## ៦- ការផ្តន្ទាទោស៖



បន្ទាប់ពីសវនាការ ប្រសិនបើអ្នកត្រូវបានរកឃើញថាមានពិរុទ្ធ ការផ្តន្ទាទោស ត្រូវតែសមាមាត្រទៅនឹងបទល្មើសដែលអ្នកបានប្រព្រឹត្ត។ តុលាការ ក៏អាចនឹងពិចារណាអំពីស្ថានសម្រាល ទៅតាមកាលៈទេសៈដែលអ្នកប្រព្រឹត្តបទល្មើស និងស្ថានភាពផ្ទាល់ខ្លួនជាក់ស្តែងរបស់អ្នកនៅពេលនោះ។ សេចក្តីសម្រេចរបស់តុលាការ នឹងត្រូវប្រកាសនៅក្នុងសវនាការសាធារណៈ ហើយត្រូវអានដោយប្រធានសវនាការ នៅថ្ងៃសវនាការនោះ ឬអាចលើកពេលប្រកាសទៅពេលក្រោយ។

## ៧- បណ្តឹងឧទ្ធរណ៍៖



ប្រសិនបើអ្នកមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់តុលាការទេ អ្នកមានសិទ្ធិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការផ្តន្ទាទោស និង / ឬ ការរកឃើញពិរុទ្ធភាពរបស់អ្នក ក្នុងរយៈពេល ១ ខែ គិតពីថ្ងៃប្រកាសសាលក្រម។ អ្នកអាចធ្វើបណ្តឹងឧទ្ធរណ៍ដោយខ្លួនអ្នក ឬតាមរយៈប្រធានពន្ធនាគារ ឬតាមរយៈមេធាវីរបស់អ្នក។ ប្រសិនបើអ្នកប្តឹងឧទ្ធរណ៍ អ្នកប្រហែលជាអាចរួចផុតពីបទចោទប្រកាន់ នៅសវនាការសាលាឧទ្ធរណ៍ ឬទោសរបស់អ្នកអាចនឹងត្រូវបានកាត់បន្ថយ។ ព្រះរាជអាជ្ញា ក៏មានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ១ ខែដូចគ្នា។ ក្នុងករណីដែលព្រះរាជអាជ្ញាប្តឹងឧទ្ធរណ៍ប្រឆាំងនឹងអ្នក អ្នកនឹងត្រូវបន្តឃុំខ្លួននៅក្នុងពន្ធនាគាររហូតដល់សាលាឧទ្ធរណ៍សម្រេច ប៉ុន្តែអ្នកនៅតែអាចស្នើសុំឲ្យដោះលែងអ្នក រហូតដល់សវនាការសាលាឧទ្ធរណ៍។ ករណីនេះ ទោសរបស់អ្នក អាចនឹងត្រូវបន្ថែមលើសពីមុន។ ប្រសិនបើអ្នក ឬព្រះរាជអាជ្ញា នៅតែមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ ភាគីទាំងពីរមានសិទ្ធិប្តឹងសារទុក្ខទៅតុលាការកំពូល។